ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាលសរុប

# របាយការណ៍ស្តីពី
## វេទិកាជាតិ អន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើប លើកទី៣

ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ០៣ រសៀល នៅនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ អគារ K, L គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដោយមានការសហការពីអង្គការកាវីតាស់កម្ពុជា បានរៀបចំវេទិកាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប លើកទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការនិមន្ត និងអញ្ជើញចូលរួមពី សម្តេចសង្ឃរាជទាំងពីរគណៈ ឯកឧត្តម ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន/អនុប្រធាននាយកដ្ឋាន និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងអង្គការកាវីតាស់អាស៊ី តំណាងអង្គការកាវីតាស់កម្ពុជា ព្រះសង្ឃទាំងពីរគណៈ តាជី យាយជី តំណាងសាសនាគ្រឹស្ទ សាសនាកាតូលិក សាសនាឥស្លាម បងប្អូនជនជាតិភាគតិច សហភាពសហព័ន្ធយុវជនកម្ពុជា យុវជនកាកបាទក្រហមកម្ពុជា យុវជនកាយរិទ្ធកម្ពុជា សិស្ស និស្សិត តំណាងអង្គការដៃគូពាក់ព័ន្ធ និងភ្ញៀវជាតិ អន្តរជាតិមួយចំនួនទៀត សរុបចំនួន ១.៤១០ អង្គ/នាក់ ។

របៀបវារៈ នៃវេទិកាជាតិ **អន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប លើកទី៣** គឺផ្តោតសំខាន់ទៅលើការអប់រំផ្សព្វផ្សាយ និងការចូលរួមសហការជាសកល តាមរយៈការបញ្ជូនសារ នៃសាសនាទាំង៤ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប ។

បន្ទាប់ពីការអញ្ជើញមកដល់សាលវេទិកាអន្តរសាសនាលើកទី៣ របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្តេចបានចុះហត្ថលេខាគាំទ្រលើផ្ទាំង (Logo) អន្តរសាសនា។ បន្ទាប់មកសម្តេចក្រឡាហោម បានផ្តល់កិត្តិយសថតរូបអនុស្សាវរីយ៍ជាមួយតំណាងសាសនាទាំង៤ តំណាងអង្គការកាវីតាស់ និងភ្ញៀវជាតិ អន្តរជាតិដែលបាននិមន្ត និងអញ្ជើញចូលរួមក្នុងវេទិកាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប លើកទី៣ នេះ។

កម្មវិធីបន្ទាប់ គឺការគោរព ទង់ជាតិ និងភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

ជាកិច្ចចាប់ផ្តើម នៃវេទិកាអន្តរសាសនាថ្នាក់ជាតិ **ឯកឧត្តម ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**ធម្មការ និងសាសនា** បានអញ្ជើញមានប្រសាសន៍ស្វាគមន៍ និងអានរបាយការណ៍សង្ខេបពាក់ព័ន្ធនឹងវិស័យសាសនាទាំង៣ ធំៗ ប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជូន **សម្តេចក្រឡាហោម** ជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ ក៏ដូចជាសម្តេចសង្ឃរាជទាំងពីរគណៈ និងឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការអគ្គនាយក អគ្គនាយករង អស់លោក លោកស្រី មន្ត្រីរាជការ តំណាងអង្គការដៃគូពាក់ព័ន្ធ ភ្ញៀវជាតិ អន្តរជាតិ តំណាងសាសនាទាំង៣ តាជី យាយជី សិស្ស និស្សិត ក្រុមយុវជនទាំងបីក្រុម និងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងកម្មវិធីវេទិកានាឱកាសនេះ។

មតិគាំទ្រ និងចំណាប់អារម្មណ៍របស់ **លោក គីម រតនា** ប្រធានអង្គការកោរីតាស់កម្ពុជា នៃវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប លើកទី៣ ។

តំណាងអង្គការកោរីតាស់អាស៊ី ឡើងមានមតិគាំទ្រ និងចំណាប់អារម្មណ៍ នៃវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប លើកទី៣ ដោយបានធ្វើការកោតសរសើរចំពោះការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ លោកបានបញ្ជាក់អំពីមូលហេតុនៃការធ្វើចំណាកស្រុក និងអំពើជួញដូរមនុស្ស គឺកើតឡើងដោយសារភាពក្រីក្ររបស់ប្រជាជន ដូច្នេះត្រូវធ្វើការផ្សព្វផ្សាយ អប់រំឲ្យបានទូលំទូលាយ ត្រូវលើកកម្ពស់ប្រជាពលរដ្ឋតាមរយៈការផ្តល់ការងារធ្វើដែលមានប្រាក់ចំណូលសមរម្យ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញឡើងអានរបាយការណ៍សង្ខេប ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងចំណាប់អារម្មណ៍ជូន **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ និងអង្គពិធីទាំងមូល ។ **លោកជំទាវ** បានមានប្រសាសន៍លើកឡើងពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថា៖ អំពើជួញដូរមនុស្ស គឺជាទម្រង់ នៃឧក្រិដ្ឋកម្មមួយ ដែលមានបណ្តាញចាត់តាំងយ៉ាងទូលំទូលាយ ភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន និងមួយចំនួន អាចកើតមាននៅក្នុងប្រទេស ហើយបច្ចុប្បន្ន អំពើជួញដូរមនុស្ស ត្រូវបានគេចាត់ទុកថាជា «ទាសភាពសម័យទំនើប» ។ **លោកជំទាវ** បានបន្តថា រៀងរាល់ថ្ងៃ មានមនុស្សក្មេងចាស់ ប្រុស ស្រី រាប់លាននាក់ក្នុងតំបន់ និងរាប់រយលាននាក់ក្នុងពិភពលោក ដែលត្រូវបានគេជួញដូរ កេងប្រវ័ញ្ចដូចសត្វធាតុ ហើយមនុស្សទាំងនោះ បានខូចខាត និងបាត់បង់សិទ្ធិសេរីភាព សុខភាពផ្លូវកាយ ផ្លូវចិត្ត រងនូវការលំបាកវេទនា ខាតបង់ទ្រព្យធន ពេលវេលា បាត់បង់ទំនាក់ទំនងផ្សាភ្ជាប់មនោសញ្ចេតនារវាងស្វាមីភរិយា ឪពុកម្តាយ បងប្អូន ញាតិមិត្ត សាច់សារលោហិត ឬរងនូវការធ្វើទារុណកម្មដោយការងារធ្ងន់ធ្ងរ គ្រោះថ្នាក់ មិនមានការថែទាំ ការសម្រាកលំហែ និងមួយចំនួន បានក្លាយជាជនពិការរាងកាយវិកលចរិក និងរហូតដល់បាត់បង់អាយុជីវិតថែមទៀត ។

**លោកជំទាវ រដ្ឋលេខាធិការ និងអនុប្រធានអចិន្ត្រៃយ៍** បានបន្ថែមថា ដោយឡែក រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ព្រមទាំង **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ ក៏ដូចជាថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់

គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ បានខិតខំប្រឹងប្រែងជំនះគ្រប់ឧបសគ្គ ក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាប សង្គ្រោះ ផ្តន្ទាទោស និងការពារជនរងគ្រោះយ៉ាងសកម្ម ។

បន្ទាប់មក **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ បានអានសារប្តេជ្ញាចិត្តរួម ចំនួន ៩ ចំណុច និងអានសារួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប ចំនួន ៣ ចំណុច ។

**កម្មវិធីបន្ទាប់ គឺពិធីសូត្រធម៌ អធិដ្ឋាន បញ្ចូនសារ នៃសាសនាទាំង៣ ធំៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា៖**

១.សាសនាព្រះពុទ្ធ

២.សាសនាគ្រឹស្ទ

៣.សាសនាឥស្លាមកម្ពុជា

ប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ក្នុងវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប លើកទី៣ ក្នុងការអនុវត្តបន្តឲ្យមានប្រសិទ្ធិភាពខ្ពស់ និងធ្វើការគាំទ្រនូវការប្រមូលផ្តុំគ្នាដើម្បីធ្វើវេទិកានេះឡើង ដោយមានការអញ្ជើញចូលរួមពីសាសនាធំៗទាំង៣ ក៏ដូចជាការចូលរួមគាំទ្រពីអង្គការកាវីតាស់ផងដែរ ។ យើងទាំងអស់គ្នាប្តេជ្ញាចិត្តធ្វើសកម្មភាពរួមគ្នា និងបន្តពង្រីកការផ្សព្វផ្សាយតាមរយៈការអប់រំតាមបែបសាសនា ដល់សាសនិកគ្រប់និកាយសាសនាទាំងអស់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យយល់ដឹង អំពីអំពើជួញដូរមនុស្ស ផលប៉ះពាល់ ល្បិចកលជនល្មើស និងនាំគ្នាលុបបំបាត់ទាសភាពសម័យទំនើបនេះ ឲ្យអស់ពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

**សម្តេចក្រឡាហោម** មានប្រសាសន៍ថា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមសម្តែងនូវការគោរព សរសើរ អស់ពីដួងចិត្ត និងសូមគាំទ្រសកម្មភាពនេះ ឲ្យមានជារៀងរហូត ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាគ្រឹះដ៏រឹងមាំនៃសីលធម៌ក្នុងការរស់នៅ ដែលនាំមកនូវសេចក្តីសុខ សន្តិភាពផ្លូវកាយ ផ្លូវចិត្តរបស់មនុស្សក្នុងសង្គម ជាសេចក្តីត្រូវការចាំបាច់ មិនអាចខ្វះបានក្នុងជីវិតរស់នៅប្រចាំថ្ងៃ ក៏ដូចជាដើម្បីលើកកម្ពស់វប្បធម៌អារ្យធម៌ដ៏ល្អផូរផង់របស់ព្រះរាជាណាចក្រកម្ពុជាដែលធ្លាប់មានតាំងពីយូរលង់មកហើយ ។ **សម្តេចក្រឡាហោម** មានប្រសាសនគាំទ្រមតិរបស់តំណាងអង្គការកាវីតាស់កម្ពុជា អំពីមូលហេតុ នៃការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ និងការជួញដូរមនុស្ស។ **សម្តេច** បានមានប្រសាសន៍លើកឡើងថា ការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម គឺវាមានមូលហេតុផ្សេងៗជាច្រើនទៀតដែលពាក់ព័ន្ធ ហើយជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស គឺមិនមែនជាអ្នកក្រទេ។

**សម្តេចក្រឡាហោម** បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ជូនសមាជិក សមាជិកា នៃវេទិកាអន្តរសាសនាលើកទី៣នេះ ក៏ដូចជាជនរួមជាតិដូចខាងក្រោម៖

- យើងត្រូវធ្វើការផ្សព្វផ្សាយអំពីល្បិចកលរបស់ជនឆបោក នៃអំពើជួញដូរមនុស្សឲ្យបានទូលំទូលាយ

- ត្រូវធ្វើការរួមគ្នា សហការគ្នា ទាំងគ្រប់វិស័យ(រដ្ឋ និងឯកជន )ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យើងមិនត្រឹមតែអនុវត្តតាមវិស័យអប់រំទេ គឺត្រូវអនុវត្តតាមវិធានការច្បាប់ផងដែរ
- ត្រូវធ្វើការកាត់ទោស និងបង្កកទ្រព្យសម្បត្តិជនល្មើសពាក់ព័ន្ធការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងជនល្មើសជួញឈើខុសច្បាប់ ។
- សមត្ថកិច្ច និងតុលាការ ត្រូវអនុវត្តការងារប្រឆាំងការជួញដូរមនុស្ស ឲ្យទទួលបានជោគជ័យ

ចុងបញ្ចប់ នៃកម្មវិធី **សម្តេចក្រឡាហោម** មានប្រសាសន៍ថា ខ្ញុំមានជំនឿយ៉ាងមុតមាំ តាមរយៈ **«វេទិកាអន្តរសាសនាថ្នាក់ជាតិ លើកទី៣»** ដែលបាន និងកំពុងតែប្រព្រឹត្តទៅក្នុងព្រះរាជាណាចក្រកម្ពុជា នាពេលនេះ នឹងជួយរួមចំណែកដល់សកម្មភាពបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឈានទៅបញ្ចប់ទាសភាពសម័យទំនើបយ៉ាងពិតប្រាកដ ។ **សម្តេច** មានប្រសាសន៍ថ្លែងនូវអំណរព្រះគុណ និងអំណរគុណ ព្រមជាមួយនឹងការកោតសរសើរដោយស្មោះ ចំពោះគំនិតផ្តួចផ្តើមរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អង្គការការីតាសកម្ពុជា និងប្រមុខដឹកនាំសាសនាទាំង៣ ក្នុងការរៀបចំឲ្យមានវេទិកាអន្តរសាសនានេះឡើង និងសូមថ្លែងអំណរគុណចំពោះស្មារតីចូលរួមគាំទ្រទាំងធនធានថវិកា កម្លាំងកាយចិត្ត របស់ក្រសួង ស្ថាប័ន និងអង្គការដៃគូទាំងអស់ រហូតដល់មានការប្រារព្ធពិធីសូត្រធម៌ អធិដ្ឋាន បញ្ជូនសារ តាំងពីលើកទី១ ក្នុងឆ្នាំ២០១៧ រហូតមក ។

បន្ទាប់មក **សម្តេចក្រឡាហោម** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់បង្ហោះសារ ស្តីពីការប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយ ឯកឧត្តម លោកជំទាវ តំណាងសាសនាទាំង៣ ព្រះសង្ឃ តាជី យាយជី មន្ត្រីរាជការ លោក លោកស្រី ភ្ញៀវកិត្តិយស សិស្ស និស្សិតដែលនិមន្ត និងអញ្ជើញចូលរួមក្នុងអង្គពិធី។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃសុក្រ ១រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩
**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ. សៅ ស៊ីនួន

បានឃើញ
06/09/19

**គោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃសុក្រ ១រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩
**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ឯក. គង់_ពុទ្ធី